ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល
លេខៈ ៤០/២៥ ស.ណ.អ.ស

# សេចក្តីជូនដំណឹង
# ស្តីពី
# ការហាមឃាត់សកម្មភាពបង្ហោះអាកាសយានគ្មានមនុស្សបើក (ដ្រូន) និងវត្ថុទាំងឡាយដែលហោះហើរបាន នៅជុំវិញអាកាសយានដ្ឋាន

យោងច្បាប់ស្តីពីអាកាសចរណ៍ស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា បទប្បញ្ញត្តិបច្ចេកទេសអាកាសចរណ៍ស៊ីវិល និងដើម្បីរក្សាសណ្តាប់ធ្នាប់របៀបរៀបរយ សិទ្ធិឯកជនភាព សន្តិសុខ សុវត្ថិភាព ប្រតិបត្តិការអាកាសយានដ្ឋាន ប្រតិបត្តិការហោះហើរ និងការគ្រប់គ្រងចរាចរណ៍ដែនអាកាសនៅក្នុងព្រះរាជាណាចក្រកម្ពុជា រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល សូមធ្វើការជូនដំណឹងដូចខាងក្រោមៈ

១. ហាមបង្ហោះអាកាសយានគ្មានមនុស្សបើក (ដ្រូន) ឬវត្ថុទាំងឡាយដែលហោះហើរបាននៅក្នុងភូមិសាស្ត្រដែលមានកាំរង្វង់ ១៥ គីឡូម៉ែត្រ ពីអាកាសយានដ្ឋាន និងតំបន់កម្រិតកំណត់ការហោះហើរ។

២. ជនណាដែលល្មើសបំពាន បង្ហោះអាកាសយានគ្មានមនុស្សបើក (ដ្រូន) ឬវត្ថុទាំងឡាយដែលហោះហើរបាន ដោយគ្មានការអនុញ្ញាត និងដោយមិនមានការជូនដំណឹងតាមរយៈ NOTICE TO AIRMEN (NOTAM) ដល់អ្នកប្រើប្រាស់ដែនអាកាសតាមនីតិវិធីរបស់រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល ឬធ្វើសកម្មភាពទាំងឡាយណាដែលអាចបង្កគ្រោះថ្នាក់ដល់ប្រតិបត្តិការអាកាសយាន ត្រូវទទួលខុសត្រូវចំពោះមុខច្បាប់ជាធរមាន។

៣. ប្រតិបត្តិករអាកាសយានដ្ឋាន ប្រតិបត្តិករអាកាសយានគ្មានមនុស្សបើក (ដ្រូន) ប្រតិបត្តិករ អ្នកផ្តល់សេវាកម្ម និងអង្គភាពពាក់ព័ន្ធនានា ត្រូវចូលរួមសហការអនុវត្ត និងផ្សព្វផ្សាយសេចក្តីជូនដំណឹងនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃអង្គារ ១១កើត ខែបុស្ស ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៨
រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ ១ ឆ្នាំ ២០២៥

**រដ្ឋមន្ត្រី**

**ម៉ៅ.ហាវណ្ណាល់**